មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៣-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១០៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **យាន សៀវដុង** (YAN XIAODONG) ជនជាតិ ចិន សញ្ជាតិចិន កើតនៅខេត្តធានជីង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **យាន ដេវីដ** (YAN DAVID) ១៤៦៩

០៤-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១១៣ ស្តីពីការប្រោសព្រះរាជទានចំពោះឧកញ៉ា **ស៊ីម ថៃ** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ១៤៧០

០៧-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១១៤ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ឯក **ញៀម ផល្លា** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ១៤៧១

០៧-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១១៥ ស្តីពីការប្រោសព្រះរាជទានចំពោះលោកស្រី **មីអេកូ អូសាណៃ** នូវគ្រឿងឥស្សរិយយស មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ១៤៧២

០៧-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១១៦ ស្តីពី :
១- តែងតាំងឯកឧត្តម **កុយ ពុំ** ជាអនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំនួសឯកឧត្តម **ម៉ាន សូរស័ក្តិ** ដែលត្រូវបានទទួលភារកិច្ចថ្មី
២- តែងតាំងឯកឧត្តម **ណី លន់** ជាអនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ជំនួសឯកឧត្តម **ផង់ សារ៉េត** ដែលត្រូវបានទទួលភារកិច្ចថ្មី ១៤៧៣

០៧-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១១៧ ស្តីពីការធ្វើសមាហរណកម្មទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិលរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈចំនួន ០២ រូប ១៤៧៤

០៧-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១១៨ ស្តីពីការតែងតាំង លោក **ខាំ រតនា** ជាឧកញ៉ា ១៤៧៦

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៤-៣-២០០៦	-អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	១៤៧៧
១៤-៣-២០០៦	-អនុក្រឹត្យលេខ ២៨ អនក្រ.បក ស្តីពីការកែសម្រួលលើមាត្រា ៤ ចំណុច ៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស	១៤៧៩
១០-៣-២០០៦	-អនុក្រឹត្យលេខ ១៥៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ	១៤៨២
១០-៣-២០០៦	-អនុក្រឹត្យលេខ ១៦០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	១៤៨៣
១០-៣-២០០៦	-អនុក្រឹត្យលេខ ១៦១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	១៤៨៤
១០-៣-២០០៦	-អនុក្រឹត្យលេខ ១៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៤៨៥
១០-៣-២០០៦	-អនុក្រឹត្យលេខ ១៦៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	១៤៨៦
១៣-៣-២០០៦	-អនុក្រឹត្យលេខ ១៦៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	១៤៨៧
១៣-៣-២០០៦	-អនុក្រឹត្យលេខ ១៦៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់	១៤៨៨
១៤-៣-២០០៦	-អនុក្រឹត្យលេខ ១៦៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៤៨៩
១៤-៣-២០០៦	-អនុក្រឹត្យលេខ ១៦៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៤៩០
១៥-៣-២០០៦	-អនុក្រឹត្យលេខ ១៦៨ អនក្រ.តត ស្តីពីការតែងតាំងសមាសភាព របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី	១៤៩១
១៥-៣-២០០៦	-អនុក្រឹត្យលេខ ១៦៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៤៩៤
១៥-៣-២០០៦	-អនុក្រឹត្យលេខ ១៧០ អនក្រ.តត ស្តីពីការជូនមេដាយការងារ	១៤៩៦
១៥-៣-២០០៦	-អនុក្រឹត្យលេខ ១៧១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៤៩៨

III-ការិយាល័យក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៣-៣-២០០៦	-ប្រកាសលេខ ១៤៧ សហវ.ឧហ ស្តីពីការផ្លាស់ប្តូរសមាជិកក្រុមប្រតិបត្តិប្រចាំ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ សំរាប់ការអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុ	១៤៩៩
១៣-៣-២០០៦	-សេចក្តីជូនដំណឹងលេខ ០០៧ សហវ.សជណ ស្តីពីការអនុវត្តន៍អាករពិសេសលើសេវាទូរស័ព្ទ	១៥០១

២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៥-៣-២០០៦ -ប្រកាសលេខ ៣០០ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **វ៉ល្សមខូខូម៉ុ អ៊ីតែរីល (ខេមបូឌា) អ៊ីន** បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមាន ឈ្មោះថា " វ៉ល្សមខូខូម៉ុ អ៊ីតែរីល (ខេមបូឌា) អ៊ីន " ១៥០២

១៥-៣-២០០៦ -ប្រកាសលេខ ៣០១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ញូ វ៉ាយដ៏ (ខេមបូឌា) ហ្គាមេន** បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមាន ឈ្មោះថា " ញូ វ៉ាយដ៏ (ខេមបូឌា) ហ្គាមេន " ១៥០៤

៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១០-០២-២០០៦ -លិខិតលេខ ៤៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេ អេស ស៊ី អិល** ១៥០៦

១០-០២-២០០៦ -លិខិតលេខ ៤៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ែរឡាញ អ៊ិនធើណេស៊ិនណល (ខេមបូឌា) ឌីវេឡុបមេន** ១៥០៨

១០-០២-២០០៦ -លិខិតលេខ ៤៤២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ថារី អ៊ិនវេសមេន** ១៥១០

១០-០២-២០០៦ -លិខិតលេខ ៤៤៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ប្លូ វេល ស៊ីតូ ណេតវើក (ខេមបូឌា)** ១៥១២

១០-០២-២០០៦ -លិខិតលេខ ៤៥៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **តាយ ណាម ខេ.អិលធីឌី** ១៥១៤

១០-០២-២០០៦ -លិខិតលេខ ៤៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **លេន ម៉ាស្ទ័រ ឌីវេឡុបមេន** ១៥១៦

១៤-០២-២០០៦ -លិខិតលេខ ៤៦៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ី អិមតីឌី & អ៊ិនជីនារីង** ១៥១៨

១៤-០២-២០០៦ -លិខិតលេខ ៤៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ជី.ប៊ី.វ៉ាយ អ៊ិនវេសមេន អេន ឌីវេឡុបមេន** ១៥២០

១៤-០២-២០០៦ -លិខិតលេខ ៤៦៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ហ្គាន យ៉ែតធីថល មេនេចមេន** ១៥២២

១៤-០២-២០០៦ -លិខិតលេខ ៤៦៩ ពណ.នតត ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេមប៊ិច ខូ អិលធីឌី** ១៥២៤

១៥-០២-២០០៦ -លិខិតលេខ ៤៧០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **(ខេមបូឌា) មីនើរ៉ល**
រីសសស៍ ឌីវេឡុបមេន ១៥២៦

១៥-០២-២០០៦ -លិខិតលេខ ៤៧៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គ្រ្យាន ប៊ុកឈើង គ្រុប** ១៥២៨

១៥-០២-២០០៦ -លិខិតលេខ ៤៧៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ធី.ធី.ខេ.អិន ផ្លាស្ទិក អ៊ីមផត**
អិចផត ១៥៣០

១៥-០២-២០០៦ -លិខិតលេខ ៤៧៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ធី អេហ្វ ខេ អេច** ១៥៣២

១៥-០២-២០០៦ -លិខិតលេខ ៤៨០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សៀមរាប ឡែន អ៊ិនវេសមេន**
ខមភេនី លីមីធីត ១៥៣៤

ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគមជាតិសាសនា ក្សត្រិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យាន សៀវដុង** (YAN XIAODONG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៦៣ នៅខេត្តជានជឹង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **យាន ដេវីដ** (YAN DAVID) ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៦០៣-១១៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មី.ន ឆ្នាំ ២០០៦

លេខ: ១០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីៈ ឆ្នាំ ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈឹម តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា ស៊ុន ថៃ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៦០៣.១១៤

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ ០៣ ឆ្នាំ ២០០៦

លេខ: ១១៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ០៣ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ . - តម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ឯក ញ៉ែម វិច្ឆរា អត្តលេខ ០៩៧៤ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ . - សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ . - ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

តរល-០៦០៣-១១៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៦

លេខ: ១១៩ - ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៣ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាអ៊ី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

- លោកស្រី មីអេកូ អូសាវ៉ៃណ

នូវ

គ្រឿងឥស្សរិយយស មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ១១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ០៣ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

ពរស.០៦០៣.១២០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មីនា ឆ្នាំ២០០៦

នស/រកត/០៣០៦/១១៦

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម កុយ ពុំ ជាអនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំនួសឯកឧត្តម ចាន់ សូរស័ក្តិ ដែលត្រូវបានទទួលភារកិច្ចថ្មី ។

មាត្រា ២: ត្រូវបានតែងតាំងឯកឧត្តម ណើ លន់ ជាអនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ជំនួសឯកឧត្តម ផង់ សារ៉េត ដែលត្រូវបានទទួលភារកិច្ចថ្មី ។

មាត្រា ៣: រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៦០៣.១២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០០៦

លេខៈ ១៦១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានធ្វើសមាហរណកម្មទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិល

របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដូចមានរាយនាមខាងក្រោម ÷

១	ឯកឧត្តម សុខ ឥសាន	ឧត្តមមន្ត្រី	ថ្នាក់លេខ ២
២	ឯកឧត្តម សំ ហ៊ាង	ឧត្តមមន្ត្រី	ថ្នាក់លេខ ៥

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០៦០៣.១៧៧

ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៦

លេខ: ១៧០ - ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាន់ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក ជា រតនា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ១១៤ . ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៣ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

ពរស-០៧០៣.១២៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៦

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...២៣៥...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការកែសម្រួលមាត្រា១
នៃអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខនស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៦/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបញ្ចប់តំណែង សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អនុលោមតាមតំរូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

មាត្រា១.-

ត្រូវបានកែសម្រួលលើមាត្រា១ ចំណុចទី២ ដោយត្រូវលប់ចេញ សមាសភាព សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង កែសម្រួលពាក្យ សហប្រធាន ដោយដាក់ពាក្យ ប្រធាន ជំនួសវិញ នៅគ្រប់ទីកន្លែង ដែលមានពាក្យសហប្រធាន នៅក្នុងអនុក្រឹត្យ លេខ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលគ្រប់ខេត្ត ក្រុង ពាក់ព័ន្ធ ទាំងអស់ សមាសភាពនានាដែលជាអនុប្រធាន និងជាសមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រី
រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គង់ វិបុល

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...២៧...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការកែសម្រួលលើ មាត្រា៤ ចំណុច ៤.១
នៃអនុក្រឹត្យ លេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខនស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៦/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបញ្ចប់តំណែងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និង សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៧អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បកចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០០៦ ស្តីពី ការកែសម្រួល

មាត្រា១ នៃអនុក្រឹត្យ លេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- អនុលោមតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

មាត្រា១.-

ត្រូវបានកែសម្រួលលើមាត្រា៤ ត្រង់ចំណុច ៤.១ និងកែសម្រួលពាក្យ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ដូចតទៅ ÷

មាត្រា៤ ចំណុច៤.១ថ្មី

-គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស:

គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស មានភារកិច្ចដោះស្រាយជាបន្ទាន់នូវរាល់កិច្ចការទាំងឡាយដែលកើតមាននៅតាមតំបន់សេដ្ឋកិច្ចពិសេសទាំងលើទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពច្បាប់ ឬដែលមានលក្ខណៈស្ថិតក្នុងសមត្ថកិច្ចចម្រុះត្រូវដោះស្រាយដោយអន្តរក្រសួង ឬអន្តរស្ថាប័ន ហើយដែលហួសពីលទ្ធភាពសម្រេចរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ឬរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

ក្រៅពីនោះគណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសក៏ទទួលភារកិច្ច ជាយន្តការទទួលពាក្យតវ៉ា នឹងដោះស្រាយសំណើតវ៉ានោះ ពីសំណាក់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ផងដែរ។

គណៈកម្មាធិការនេះ មានទីតាំងនៅទីស្នាក់ការក្រុមប្រឹក្សា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាក្នុងកិច្ចការងាររបស់ខ្លួន។

សមាសភាពរបស់គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសមានដូចតទៅ ÷

១-	ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	ជាប្រធាន
២-	រដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៣-	រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៤-	រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម	សមាជិក
៥-	រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៦-	រដ្ឋមន្ត្រីក្រសួងបរិស្ថាន	សមាជិក
៧-	រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៨-	រដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន	សមាជិក

៩- រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១០- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១១- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ជាលេខាធិការ

ក្នុងករណីចាំបាច់ គណៈកម្មាធិការនេះអាចអញ្ជើញ សមាជិកណាមួយនៃក្រុមប្រឹក្សា ដើម្បីចូលរួមប្រជុំ នៅរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការនេះ ។ សម័យប្រជុំរបស់គណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសប្រព្រឹត្តទៅ តាមការកោះអញ្ជើញប្រជុំរបស់លេខាធិការរបស់គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស ផ្អែកតាមការកំណត់ណែនាំរបស់ប្រធាននៃគណៈកម្មាធិការនេះ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលគ្រប់ខេត្តក្រុង និងអង្គភាពពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៦

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គង់ វិបុល

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥១ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការផ្ដល់មេដាយការងារ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **គង់ សំអឿន** អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អក្នុងការចូលរួមសហការ សាងសង់មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជនពិការដោយសង្គ្រាម នៅខេត្តបន្ទាយមានជ័យ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៦០...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៛

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **សរ ចំរុង** អភិបាលរងខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អក្នុងការចូលរួមសហការជួយសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការដោយសង្គ្រាម នៅខេត្តបន្ទាយមានជ័យ ដែលជាអំណោយរបស់អង្គការ CWARS ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ២ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៦១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ជាសមាជិកអង្គការ **SCHOOL AID JAPAN** ប្រចាំកម្ពុជា និងមន្ត្រីអ្នកសំរបសំរួល ដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ ក្នុងការស្វែងរកជំនួយ ជួយកសាងសមិទ្ធផល លើវិស័យអប់រំនៅខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តក្រចេះ និងខេត្តកំពង់ស្ពឺ នៃ ព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :

ក/ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ជូនចំពោះ :

- ១-លោក **SUMITA Heikichi** នាយកប្រតិបត្តិអង្គការ **School Aid Japan**
- ២-លោកស្រី **ឆេត ជេរី** តំណាងអង្គការ **School Aid Japan** ប្រចាំកម្ពុជា
- ៣-លោក **រាជ សុគន្ធ** អនុប្រធាននាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងមហាផ្ទៃ ជាអ្នកសំរបសំរួល
- ៤-លោក **ជា ម៉ុឌ** អនុប្រធាននាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងមហាផ្ទៃ ជាអ្នកសំរបសំរួល

ខ/ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ជូនចំពោះ :

- ១-លោក **ហួន ម៉ាអុន** ជាអ្នកសំរបសំរួល

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៦៧...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ៈ ត្រូវបានចំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន០៤គ្រឿង ជូនអង្គភាព និង សប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងវិហារឥស្លាម ០១ខ្នង នៅឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-**អង្គភាព តួមិស្វាយចាក់** ថវិកា ចំនួន ១៣.០០៨ ដុល្លារ

២-លោក **ហ៊ីល ឆេខ** ថវិកា ចំនួន ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោកស្រី **យ៉ា គីរីស់** ថវិកា ចំនួន ៥.០០០ ដុល្លារ

២-លោកស្រី **នីន ហ្វានីម៉ាស់** ថវិកា ចំនួន ៥.០០០ ដុល្លារ

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៣៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សាលាខេត្តសៀមរាប

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជនជប៉ុន ចំនួន០២រូប ដែល មានចំណាយថវិកាផ្ទាល់ខ្លួន ជួយកសាងសាលារៀន ចំនួន ៤ខ្នង មាន២១បន្ទប់ និងអណ្តូងស្នប់ ចំនួន ៦៧២អណ្តូង ជូនដល់ប្រជាពលរដ្ឋនៅតាមបណ្តាស្រុកមួយចំនួន ក្នុងខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :-

១-អ្នកស្រី YOSHIDA YOSHIKO កសាងអគារសិក្សា ចំនួន ៤ខ្នង មាន២១បន្ទប់ អស់ថវិកា ចំនួន ១០៨.០០០ ដុល្លារអាមេរិក ។

២-លោក TAGUCHI YOSHITAKA កសាងអណ្តូងស្នប់ ចំនួន ៦៧២ អណ្តូង អស់ថវិកា ចំនួន ១២០.៩៦០ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ៣ ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ សេនា ចំនួន ០៣គ្រឿង ជូនថ្នាក់ដឹកនាំក្រសួងសុខាភិបាល ដែលមានស្នាដៃល្អក្នុងការខិតខំប្រឹងប្រែងបំពេញភារកិច្ច ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **តែ គុយសៀង** អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ

២-ឯកឧត្តម **ឆេព លន់** អគ្គនាយកបច្ចេកទេសសុខាភិបាល

៣-ឯកឧត្តម **លឹម ដារាមាណី** អគ្គាធិការ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៦៥. អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : តែងតាំងលោក ម៉ីន គុម្ពៈ ជាទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋសឹង្ហបុរី ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៦.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/ ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១: តែងតាំងលោក **កៅ ស៊ីវឌ្ឍ** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ី២ ជាប្រធាននាយកដ្ឋានអឺរ៉ុប នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជំនួសលោក **អោក ទើន** ដែលត្រូវបានទទួលភារកិច្ចថ្មី។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦២៧. អនក្រ-បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/ ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១: តែងតាំងលោក **អោក ទ័ត** បច្ចុប្បន្នប្រធាននាយកដ្ឋានអឺរ៉ុប ជាជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ១៦៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-យោងតាមតម្រូវការចាំបាច់

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងសមាសភាពរបស់អាជ្ញាធរជាតិ ដោះស្រាយទំនាស់ដីធ្លី ដែលមានរាយនាម ដូចខាងក្រោមនេះ

១- ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២- ឯកឧត្តម **អ៊ឹម ឈុនលឹម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធានទី ១

៣- លោកជំទាវ **ម៉ែន សំអន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អនុប្រធាន

៤- ឯកឧត្តមបណ្ឌិតរដ្ឋ **ឃាង ខៀវមុនីនារ** ទីប្រឹក្សារាជរដ្ឋាភិបាល អនុប្រធាន

៥- ឯកឧត្តម **អេង ឈៃអ៊ាង** សមាជិករដ្ឋសភា អនុប្រធាន

៦- ឯកឧត្តម **ទិម យ៉ុនឡេង** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អនុប្រធាន

៧- ឯកឧត្តម **មុំ ម៉ារ៉ែន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន សមាជិក

៨- ឯកឧត្តម **ចំរុង សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៩- ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

១០- ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១១- ឯកឧត្តម **ខៀវ សន** សមាជិករដ្ឋសភា សមាជិក

១២- ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១៣- ឯកឧត្តម **នុត សារអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៤- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៥- ឯកឧត្តម **វ៉េង សារ៉ែត** រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧត្តុនិយម សមាជិក

១៦- ឯកឧត្តម **យឹម សារិទ្ធ** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១៧- ឯកឧត្តម **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ សមាជិក

១៨- ឯកឧត្តម **គន់ គីម** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរៈភូមិន្ទ សមាជិក

១៩- ឯកឧត្តម **មាស សុភា** មេបញ្ជាការកងទ័ពជើងគោក សមាជិក

២០-ឯកឧត្តម **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២១-ឯកឧត្តម **អ៊ុង សំខាន់** មេបញ្ជាការកងទ័ពជើងទឹក សមាជិក

២២- ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

២៣- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

២៤- ឯកឧត្តម **ឡុង ឆរិទ្ធ** មេធាវីរាជរដ្ឋាភិបាល សមាជិក

២៥- ឯកឧត្តម **តិច ចាន់តារា** គណៈកម្មាធិការសិទ្ធមនុស្សកម្ពុជា សមាជិក

មាត្រា ២ : អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសមាសភាពដូចខាងក្រោមនេះ :

១- ឯកឧត្តម **ស្វាយ ស៊ីថា** អគ្គលេខាធិការ

២-ឯកឧត្តម **នូ គៀង** អគ្គលេខាធិការរង

៣- ឯកឧត្តម **ឈួន សុធី** អគ្គលេខាធិការរង

៤- ឯកឧត្តម **ឈឹម សៅរី** អគ្គលេខាធិការរង

៥- ឯកឧត្តម **អ៊ុន ទីវង់តិ** អគ្គលេខាធិការរង

៦- ឯកឧត្តម **ផល់ ចន្ទតារា** អគ្គលេខាធិការរង

៧-ឯកឧត្តម **នី សុគន្ធ** អគ្គលេខាធិការរង

4

៨-ឯកឧត្តម **ឈៅ ឆួត** អគ្គលេខាធិការរង

៩- ឯកឧត្តម **នៃ ស៊ុណារិទ្ធ** អគ្គលេខាធិការរង

១០-ឯកឧត្តម **ទាំ ឈុងវា** អគ្គលេខាធិការរង

១១- លោក **សួន សុផារ** អគ្គលេខាធិការរង

១២-លោក **ឈិន សារិទ្ធ** អគ្គលេខាធិការរង

១៣-ឯកឧត្តម **ម៉ូន លឹមហេង** សមាជិក

១៤-លោក **ហែល ចំរើន** សមាជិក

១៥-លោក **ឈៀង ផាន់ណារិទ្ធ** សមាជិក

១៦-លោកស្រី **អ៊ុក ស៊ីហា** សមាជិក

១៧-លោក **ហ៊ុយ យាង** សមាជិក

១៨-លោក **ខា សំអាង** សមាជិក

១៩-លោក **ម៉ក់ ចាន់ណារិទ្ធ** សមាជិក

២០-លោកនាយកខុទ្ទកាល័យសាលាខេត្ត ក្រុង សមាជិក

មាត្រា ៣ : អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធបង្កើតនាយកដ្ឋានមួយចំនួនទៅតាមតំរូវការចាំបាច់របស់ខ្លួន ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តក្រុង និងមន្ត្រីដែលពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្ត អនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចមាត្រា ៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៧៩...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាជិកក្រុមការងារចំរុះជាតិ ចំនួន ១២រូប ដែលបានចុះពិនិត្យវាស់ភ្នែក និងផ្តល់វ៉ែនតា ជូនប្រជាពលរដ្ឋ នៅស្រុកកំពង់បាយ និងស្រុកកំពត ខេត្តកំពត សរុបចំនួន ១៨.០០០ នាក់ ដោយចំណាយអស់ថវិកា សរុបចំនួន ១៧៥.៥០០ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

១-**Mr.ROBERT KEE** **(Founder & Director The Operation Hope Foundation Ltd)**

២-**Mr.LING SWEE CHAN** **(Director The Operation Hope Foundation Ltd)**

៣-**Mr.TIMOTHY CHAN** **(Operations Manager The Operation Hope Foundation Ltd)**

៤-**Mr.KEN JUNG** **(Past President Lions Club of Singapore Bedok)**

៥-**Mr.MARK DURKAN** **(Director of Global Operation Gift of Sight Foundation)**

៦-**Mr.TOH KENG CHOO** **(Toh Foundation)**

៧-**Mr.JAKQUELINE KHOO** **(Khoo Foundation)**

៨-**Mr.HAILU BEREKET** **(Lab. Manager)**

៩-**Dr.DOUGLAS KIEFER** **(Optometrist)**

១០-**Mr.BRYAN TIMOTHY** **(IMS . Rep assistant Lab Manager)**

១១-Mr.MICHAEL BOWEN (RD. Expert UK)

១២-Mr.TERRY .N. WOOD (RD. Expert UK)

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ /.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូននាយទាហាន នាយទាហានរង និង ពលទាហានចំណុះតំបន់ប្រតិបត្តិការសឹករងកោះកុងដែលមានស្នាដៃល្អក្នុងការបំរើជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក. <u>មេដាយមាសការងារ</u> :

១-វរសេនីយ៍ទោ	**សុខសុវត្ថិ នុម**	០០២៨៣៩	មេបញ្ជាការរង និងជានាយសេនាធិការ តំបន់ប្រតិបត្តិការសឹករងកោះកុង
២-វរសេនីយ៍ទោ	**ចុខ ម៉ិន**	០០០៩៥១	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកោះកុង
៣-វរសេនីយ៍ទោ	**សោម សាមិទ្ធ**	០០០៩៥០	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកោះកុង
៤-វរសេនីយ៍ទោ	**ខឹន សារ៉ែត**	០០២៨០៨	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកោះកុង
៥-វរសេនីយ៍ទោ	**ហែម ខាម**	០០៣៦២៤	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកោះកុង
៦-វរសេនីយ៍ទោ	**គង់ សាមីអ៊ី**	០០៨៩៤៤	នាយផ្នែកអត្តសញ្ញាណប័ណ្ណ ការិយាល័យទី១ កងទ័ពជើងគោក

ខ. <u>មេដាយប្រាក់ការងារ</u> :

១-វរសេនីយ៍ត្រី	**កែវ វិចិត្រ**	០១០៥៣៩	នាយរងសេនាធិការ	តំបន់ប្រតិបត្តិការសឹករងកោះកុង
២-វរសេនីយ៍ត្រី	**នេត វណ្ណី**	០០៣៤៨៨	នាយរងសេនាធិការ	តំបន់ប្រតិបត្តិការសឹករងកោះកុង
៣-វរសេនីយ៍ត្រី	**ចាន់ សិទ**	០១៥៦៧០	នាយរងសេនាធិការ	តំបន់ប្រតិបត្តិការសឹករងកោះកុង
៤-អនុសេនីយ៍ឯក	**អ៊ុខ ចារីជាតិ**	០១០៥៤៨	នាយការិយាល័យទី ១	តំបន់ប្រតិបត្តិការសឹករងកោះកុង
៥-អនុសេនីយ៍ឯក	**ឈឹន អន**	០១០៥៤០	នាយការិយាល័យទី ៤	តំបន់ប្រតិបត្តិការសឹករងកោះកុង
៦-អនុសេនីយ៍ឯក	**ខួន សុទ្ធ**	០១៥៦៥៨	នាយការិយាល័យទី ៥	តំបន់ប្រតិបត្តិការសឹករងកោះកុង
៧-អនុសេនីយ៍ឯក	**ចឹក ម៉ុន**	០១០៥៤២	មេបញ្ជាការវរសេនាតូចលេខ ១	តំបន់ប្រតិបត្តិការសឹករងកោះកុង

៨-អនុសេនីយ៍ឯក អ៊ុន ផា ០១០៥៥០ មេបញ្ជាការវរសេនាតូចលេខ ២ តំបន់ប្រតិបត្តិការសឹករងកោះកុង

៩-អនុសេនីយ៍ឯក ចំរើន សាខន ០១០៥៣៧ មេបញ្ជាការវរសេនាតូចលេខ ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង

១០-អនុសេនីយ៍ឯក ខា សារិន ០២១៨១០ នាយរងផ្នែកសរសេរ ការិយាល័យទី១ កងទ័ពជើងគោក

គ- មេដាយសេវាកម្មការងារ :

១-អនុសេនីយ៍ឯក យឹម ផាម៉ុន ០១៥៦៤៩ នាយហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករងកោះកុង

២-អនុសេនីយ៍ឯក ខ៊ែត ឌី ០១៥៦៦២ នាយលេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករងកោះកុង

៣-អនុសេនីយ៍ឯក ឡុច ជួន ០១០៥៤៣ មេបញ្ជាការរងវរសេនាតូចលេខ ១ តំបន់ប្រតិបត្តិការសឹករងកោះកុង

៤-អនុសេនីយ៍ឯក អ៊ុច ចាន់ថន ០១៥៦៥២ នាយការិយាល័យទី ២ តំបន់ប្រតិបត្តិការសឹករងកោះកុង

៥-អនុសេនីយ៍ឯក អ៊ុខ ម៉ុនថា ០១០៥៥៣ មេបញ្ជាការផ្នែកសឹករងស្មាច់មានជ័យ តំបន់ប្រតិបត្តិការសឹករងកោះកុង

៦-អនុសេនីយ៍ឯក នុត ណារ៉ា ០២២៣០៨ មេបញ្ជាការផ្នែកសឹករងស្រែអំបិល តំបន់ប្រតិបត្តិការសឹករងកោះកុង

៧-អនុសេនីយ៍ឯក ទ្រាក់ យន្ត ០២៩២៧៧ នាយរងការិយាល័យទី ២ តំបន់ប្រតិបត្តិការសឹករងកោះកុង

៨-អនុសេនីយ៍ឯក ស៊ូ ទណ្ឌី ០២៩២៩២ នាយការិយាល័យទី ៣ តំបន់ប្រតិបត្តិការសឹករងកោះកុង

៩-អនុសេនីយ៍ឯក សួន ចាន់ ០២៩២៩១ នាយការិយាល័យហ្វឹកហ្វឺន តំបន់ប្រតិបត្តិការសឹករងកោះកុង

១០-អនុសេនីយ៍ទោ ចក់ ចំណាន ០២៩៣០១ នាយសេនាធិការវរសេនាតូចលេខ២ តំបន់ប្រតិបត្តិការសឹករងកោះកុង

១១-អនុសេនីយ៍ទោ ភាព កុសល ០២៩២៨០ នាយរងការិយាល័យទី ១ តំបន់ប្រតិបត្តិការសឹករងកោះកុង

១២-អនុសេនីយ៍ទោ ពោ សារិន ០១៥៦៦៧ នាយរងការិយាល័យទី ១ តំបន់ប្រតិបត្តិការសឹករងកោះកុង

១៣-អនុសេនីយ៍ទោ គឹម សារ៉ាន់ ០១៥៦៥៤ នាយរងការិយាល័យជីវពល តំបន់ប្រតិបត្តិការសឹករងកោះកុង

១៤-អនុសេនីយ៍ទោ មីន សុផុន ០១៥៦៦៨ នាយសេនាធិការវរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង

១៥-អនុសេនីយ៍ទោ ម៉ៅ ម៉ុនថន ០១៥៦៧១ មេបញ្ជាការកងអនុសេនាធំលេខ ១ វរសេនាតូចលេខ ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង

១៦-ព្រិន្ទបាលឯក សែម មុត ១៥៨០៣៧ មេបញ្ជាការកងអនុសេនាតូច ១ កងអនុសេនាធំ ៣ វរសេនាតូចលេខ ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង

១៧-ព្រិន្ទបាលឯក ខា សុវណ្ណ ១៥៧៩២៨ ជំនួយការប្រតិបត្តិការវរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកោះកុង

១៨-ព្រិន្ទបាលឯក សែ សិន ១៥៧៨៩៣ ជំនួយការបុគ្គលិកវរសេនាតូចលេខ២ តំបន់ប្រតិបត្តិការសឹករងកោះកុង

១៩-ពលបាលឯក អ៊ុខ ទ្រឿង ១៥៧៨៩៣ មេក្រុមអនុសេនាធំលេខ ២ វរសេនាតូចលេខ ២តំបន់ប្រតិបត្តិការសឹករងកោះកុង

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០១ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....១៧៣០....អនក្រ.បក-៩៩

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលក្រុងកែប

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ចំនួន០៦រូប ដែលបានបរិច្ចាគនូវកម្លាំងកាយ ចិត្ត និងធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តភ្នំសរសៀ សង្កាត់អូរក្រសា ខណ្ឌដំណាក់ចង្អើរ ក្រុងកែប ដូចមានព្រះនាម និងនាមខាងក្រោម :-

១-ព្រះតេជគុណ **ពេជ សុនី**	ព្រះចៅអធិការវត្តភ្នំសរសៀ បានដឹកនាំកសាងសមិទ្ធផលនានា ក្នុងវត្តអោយមានការរីកចំរើនឥតឈប់ឈរ ។	
២-ឧបាសិកា **អ៊ីវ មួយហេងជា**	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.៣០០ ដុល្លារ
៣-លោកវេជ្ជបណ្ឌិត **ឡៅ វណ្ណា**	អនុប្រធានមន្ទីរ សុខាភិបាលខេត្តកំពត	ថវិកាចំនួន ១០.២០០ ដុល្លារ
៤-ឯកឧត្តម **អាន ហេ**	តំណាងរាស្ត្រមណ្ឌលក្រុងកែប	ថវិកាចំនួន ១២.០០០ ដុល្លារ
៥-លោក **ឌេត យុទ្ធី**	អភិបាល ខណ្ឌដំណាក់ចង្អើរ	ថវិកា ចំនួន ៣.០០០ ដុល្លារ និង ៣៥.០០០.០០០ រៀល
៦-លោកស្រី **អ៊ុយ ជ្រាន**	សប្បុរសជន នៅក្រុងកែប	ថវិកាចំនួន ១១.០០០ ដុល្លារ និង ២០.០០០.០០០ រៀល

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលក្រុងកែប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ០២ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៤៧ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦

ប្រកាស

ស្តីពី

ផ្លាស់ប្តូរសមាជិកក្រុមប្រតិបត្តិប្រចាំ

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ សំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹតទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹតលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
